# គោលបំណងនៃការចិញ្ចឹមជ្រូក

**ការចិញ្ចឹមជ្រូកមាន ៥ ចំណុចសំខាន់គឺ**

១. ការជ្រើសរើសពូជ
២. ការផ្តល់ចំណី
៣. ការធ្វើទ្រុង
៤. ការថែទាំ និងការធ្វើអនាម័យ
៥. ការការពារ និងការព្យាបាល

ការចិញ្ចឹមជ្រូកដើរតួនាទីយ៉ាងសំខាន់ចំពោះកសិករកម្ពុជាយើង ។ ការចិញ្ចឹមជ្រូកចែកចេញជា២ផ្នែកសំខាន់ៗ គឺ ចិញ្ចឹមយកសាច់ និង ចិញ្ចឹមយកកូន ។

## ផលប្រយោជន៍នៃការចិញ្ចឹមជ្រូក

-ផ្តល់សាច់មានឱជារសឆ្ងាញ់ (មានប្រូតេអ៊ីន)

-ផ្តល់ប្រាក់ចំណូលឱ្យគ្រួសារ

-ផ្តល់លាមកសំរាប់ធ្វើជី

-បង្កើនមុខរបរឱ្យកសិករ

## ជ្រូកជាសត្វងាយចិញ្ចឹម

-ស៊ីចំណីអាហារមិនរើស

-សាយកូនពី ៨-១២ ក្បាល ក្នុង ១ លើក

-រីកលូតលាស់ធំធាត់រហ័ស ៥-៧ ខែ ៨0-១00 គីឡូក្រាម

# ការចិញ្ចឹមជ្រូក

## I-ការចិញ្ចឹមជ្រូក

### ១-ពូជជ្រូកមាន ៣ ប្រភេទ

ក/ ពូជក្នុងស្រុក (ហៃណាំ, ពូជកណ្ដុរ, ពូជកំពត, ពូជដំរី)

ខ/ ពូជនាំចូល (យ៉កសៀ ឬឡាចវ៉ាយ, ឡែនរ៉ាស, ឌុយរ៉ុក)

គ/ ពូជកូនកាត់ (បានមកពីពូជក្នុងស្រុកបង្កាត់ជាមួយពូជនាំចូល)